# អ្នកនាំសារ
The Messenger

47

ថ្ងៃទី០១-១៥ ខែឧសភា ឆ្នាំ២០០៧- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៍កាតូលិកប៉ុណ្ណោះ



## ឆ្នាំកុរ ៖ គោឧសភរាជ សោយតែពោត



ទស្សនៈផ្សេងៗ ចំពោះសីលធម៌យុវវ័យ
ទំព័រ ៦



អគារថ្មីនាំមកនូវក្ដីសង្ឃឹមថ្មី ដល់កុមារាកុមារី
ទំព័រ ៩

វិធីសាស្ត្រ ចិញ្ចឹមមាន់តាមបែបធម្មជាតិ
ទំព័រ ១១

## ស្វែងយល់ពីប្រទេសកម្ពុជា


Photo: DR

នៅអ្នកនាំសារលេខមុន ប្រិយមិត្តបានស្គាល់ខ្លះៗ រួចមកហើយអំពីទំហំផ្ទៃដី ចំនួនស្រុក-ខណ្ឌ ឃុំ-សង្កាត់ ភូមិ និងចំនួនប្រជាជននៅតាមខេត្តមួយចំនួន។

ចុះតើក្រុងព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកោះកុង ខេត្តកំពង់ចាម និងខេត្តបាត់ដំបង មានទំហំផ្ទៃដី ចំនួនស្រុក-ខណ្ឌ ឃុំ-សង្កាត់ ភូមិ និងប្រជាជនមានចំនួនប៉ុន្មាននាក់ដែរ ?

ចម្លើយ : តាមស្ថិតិឆ្នាំ២០០២

ក. ក្រុងព្រះសីហនុ
- មានផ្ទៃដីចំនួន ៨៦៨ គម²
- មានចំនួន ៣ ខណ្ឌ សង្កាត់ចំនួន ២២
- ស្មើនឹងចំនួន ៨៥ ភូមិ។
- ប្រជាជនមានចំនួន ២១៦ ២១៩ នាក់។

ខ. ខេត្តកំពង់ស្ពឺ
- មានផ្ទៃដី ៧ ០១៧ គម²
- មានចំនួន ៨ ស្រុក ឃុំចំនួន ៨៩
- ស្មើនឹងចំនួន ១ ៣១៩ ភូមិ។
- ប្រជាជនមានចំនួន ៧៤៥ ៧៣០ នាក់។

គ. ខេត្តកោះកុង
- មានផ្ទៃដីចំនួន ១១ ១៦០ គម²
- មានចំនួន ៨ ស្រុក ឃុំចំនួន ៣២
- ដែលស្មើនឹង ១២៧ ភូមិ។
- ប្រជាជនមានចំនួន ១៩៩ ៤១៣ នាក់។

ឃ. ខេត្តកំពង់ចាម
- មានផ្ទៃដីចំនួន ៩ ៧៧៩ គម²
- មានចំនួន ១៦ ស្រុក ឃុំចំនួន ១៧៣។
- ប្រជាជនមានចំនួន ១ ៨៨៥ ៣៣៥ នាក់។

ង. ខេត្តបាត់ដំបង
- មានផ្ទៃដីចំនួន ១១ ៧០២ គម²
- មានចំនួន ១២ ស្រុក ឃុំចំនួន ៨៩
- ដែលស្មើនឹង ៦១១ ភូមិ។
- ប្រជាជនមានចំនួន ១ ០១៦ ៧៣៤ នាក់។

អ្នកនាំសារ



### ថ្ងៃអាទិត្យបុណ្យចម្លងទី៦ (ថ្ងៃទី១៣ ឧសភា ឆ្នាំ២០០៧)

**“ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំឱ្យអ្នករាល់គ្នា”** (យ៉ូហាន ១៤,២៣-២៩)

តាមព្រះយេស៊ូ អ្នកស្រឡាញ់ព្រះអង្គ គឺមិនគ្រាន់តែជឿ និងមិនគ្រាន់តែមានមនោសញ្ចេតនាស្រឡាញ់ប៉ុណ្ណោះទេ ជាអ្នកខិតខំប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ។ ទោះបីយើងពុំពឹងផ្អែកលើបុណ្យកុសលក្តី ក៏ការប្រព្រឹត្តនេះ គឺបានបញ្ជាក់ជំនឿ និងសេចក្តីស្រឡាញ់របស់ខ្លួន ដូចលោកយ៉ាកុបតែងបញ្ជាក់ថា “ប្រសិនបើអ្នកពោលថា ខ្លួនមានជំនឿ តែមិនប្រព្រឹត្តអំពើល្អ តើមានប្រយោជន៍អ្វី?” (យក២,១៤)។ ប៉ុន្តែយើងជាគ្រីស្តបរិស័ទដឹងច្បាស់ថា យើងពុំងាយធ្វើតាមព្រះបន្ទូលព្រះអង្គបានជាប់ជានិច្ចទេ ព្រោះយើងគឺជាមនុស្សមានតណ្ហា មិនមែនជា “ព្រះ” ទេ។ តែយើងមានព្រះវិញ្ញាណព្រះយេស៊ូគង់នៅក្នុងខ្លួន ព្រះវិញ្ញាណនេះជាឫទ្ធានុភាព និងជាព្រះហឫទ័យស្រឡាញ់នៃព្រះជាម្ចាស់ ជា “ព្រះដែលជួយការពារ” យើងឱ្យរួចពីកម្លាំងតណ្ហា ដែលមាននៅក្នុងខ្លួនយើងផ្ទាល់ និងជួយយើងឱ្យរួចពីអ្នកដែលចោទប្រកាន់យើងថា ជាអ្នកក្បត់សាសនាជាតិ ឱ្យយើងមានកម្លាំងតស៊ូនឹងអ្នកបង្ខូចយើងផ្តេសផ្តាស។ល។ បើគេធ្វើបាបម្ចាស់យើង មុខជាគេនឹងធ្វើបាបយើងដូចព្រះអង្គមិនខាន។

ប៉ុន្តែក្នុងគ្រាដ៏ពិបាកទាំងនេះ យើងគឺត្រូវរំលឹកគិតថា ព្រះបិតា ព្រះយេស៊ូ និងព្រះវិញ្ញាណ គង់នៅក្នុងខ្លួនយើង។ ខ្លួនយើងក្លាយទៅជាព្រះវិហារសម្រាប់ព្រះត្រៃឯកគង់នៅ។ នេះជាសេចក្តីសុខសាន្តរបស់យើង! ទោះបីជាគេធ្វើបាបយើងក្តី ទោះបីយើងដឹងខ្លួនថា យើងជាមនុស្សបាប និងមិនសូវល្អក្តី ក៏យើង នៅមានសេចក្តីសុខសាន្តក្នុងចិត្ត ពីព្រោះព្រះត្រៃឯកនៅជាមួយយើងជានិច្ច។ គឺគ្មានអ្វីដែលអាចបណ្តាលឱ្យព្រះអង្គឃ្លាតចេញចាកពីយើងបានឡើយ។



### ថ្ងៃអាទិត្យលើកតម្កើងព្រះយេស៊ូដែលទទួលព្រះជន្មដ៏រុងរឿង (ថ្ងៃទី២០ ឧសភា ឆ្នាំ២០០៧)

**“ព្រះជាម្ចាស់ប្រទានឱ្យអ្នករាល់គ្នាមានឫទ្ធានុភាព”** (លូកា ២៤,៤៦-៥៣)

លោកលូកាតែម្នាក់ឯង ជាអ្នកនិពន្ធគម្ពីរកិច្ចការគ្រីស្តទូត (អត្ថបទទី១) និងគម្ពីរដំណឹងល្អ រៀបរាប់ពីព្រះជាម្ចាស់លើកព្រះយេស៊ូឡើងតាមរបៀបផ្សេងពីគ្នា គឺនៅគម្ពីរកិច្ចការ ព្រះជាម្ចាស់លើកព្រះយេស៊ូឡើង សែសិបថ្ងៃ ក្រោយពេលព្រះអង្គទទួលព្រះជន្មថ្មីដ៏រុងរឿង រីឯក្នុងគម្ពីរដំណឹងល្អវិញ ព្រះជាម្ចាស់លើកព្រះយេស៊ូនៅល្ងាចថ្ងៃបុណ្យចម្លង។ របៀបនិពន្ធបញ្ជាក់ថា ព្រះជាម្ចាស់ដែលប្រោសលោកយេស៊ូឱ្យទទួលព្រះជន្មថ្មី និងលើកព្រះយេស៊ូឡើង គឺជាព្រឹត្តិការណ៍មានអត្ថន័យដ៏ជ្រៅ។

នៅក្នុងអត្ថបទគម្ពីរដំណឹងល្អ លោកលូកាចង់ពន្យល់ថា សព្វថ្ងៃអ្នកជឿអាចស្គាល់ព្រះយេស៊ូបានដោយអាន និងស្និទ្ធស្នាលនឹងព្រះគម្ពីរ នឹកដល់ព្រះអង្គ ដោយប្រកាសជំនឿរបស់ខ្លួន និងលើកតម្កើងព្រះជាម្ចាស់ផងដែរ។ យើងជាអ្នកជឿ អាចធ្វើជាសាក្សីពីព្រះអង្គបានដោយឫទ្ធានុភាពនៃព្រះវិញ្ញាណ ស្ថិតនៅជាមួយយើង។ ព្រះយេស៊ូប្រទានពរឱ្យសាវ័កក្នុងឋានៈជាមហាបូជាចារ្យ។ សាវ័កទទួលស្គាល់ថា ព្រះអង្គជាព្រះអម្ចាស់។ ព្រះបិតាលើកលោកយេស៊ូឡើង គឺដូចព្រះអង្គលើកព្យាការីអេលីពីដើមដែរ។ ចំណែកក្នុងអត្ថបទគម្ពីរកិច្ចការវិញ លោកលូកាចង់ពន្យល់ថា យើងពុំងាយជឿថាព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿងទេ។ យើងត្រូវទទួលនូវការអប់រំពិសេស “អស់សែសិបថ្ងៃ” និងត្រូវទេវទូតពន្យល់ផង ទើបអាចយល់ខ្លះៗបាន។ ទោះជាយ៉ាងណាក៏ដោយ យើងមានអំណរសប្បាយដោយសារតែមានមនុស្សម្នាក់ដូចជាយើងបេះបិទ ទទួលឋានៈជាព្រះអម្ចាស់ គង់នៅស្ថានបរមសុខ (នៅលើពពក) ជួយអង្វរព្រះបិតាឱ្យយើង។



សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !





## សកម្មភាពផ្សេងៗ...



ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា យាងមកធ្វើជាព្រះអធិបតីភាពក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០០៧។ ព្រះអង្គលើកព្រះហស្តស្វាគមន៍ប្រជារាស្ត្ររបស់ព្រះអង្គ។

អ្នកអម្ចាស់នរោត្តម សិរិវុឌ្ឍ ត្រូវបានសព្វព្រះរាជហឫទ័យជ្រើសតាំងដោយព្រះករុណា ព្រះមហាក្សត្រ ធ្វើជាស្តេចនាគក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លដ៏ឧដុង្គឧត្តម។ ព្រះអម្ចាស់កំពុងត្រូវបានដង្ហែទៅកាន់ព្រះស្រែក្នុងពេលដំណើរពិធី







លើ : អ្នកម្នាងជាព្រះមេហ៊ូព្រោះស្រូវទៅក្នុងវាលព្រះស្រែ បន្ទាប់ពីស្តេចនាគបានភ្ជួររួច បួងសួងឱ្យការបង្កើនផលបានល្អ
ឆ្វេង : ភ្ញៀវបរទេសចូលទស្សនាព្រះរាជពិធីច្រត់ព្រះនង្គ័ល

Photographed by L. Sovanna



## លិខិតពីតេហ្សេ

យើងទាំងអស់គ្នាសួរគ្នាទៅវិញទៅមកអំពីរបៀបរស់នៅ។ តើយើងត្រូវសម្រួលការរស់នៅរបស់យើងដោយរបៀបណា ? នោះគឺយើងត្រូវសម្រួលរបៀបរស់នៅឱ្យសាមញ្ញ និងរាបសា ពេលនោះយើងនឹងស្រឡះចិត្ត ហើយអាចបើកចិត្តគំនិតទទួលអ្នកដទៃទៀត។ ដើម្បីឱ្យការរស់នៅយើងមានលក្ខណៈជាមនុស្សជាតិកាន់តែប្រសើរឡើងៗ ការលះបង់ពេលវេលាសម្រាប់អ្នកដទៃគឺល្អប្រសើរលើសលប់។ មនុស្សយើងម្នាក់ៗ អាចស្វែងរកមធ្យោបាយដើម្បីស្តាប់និងគាំទ្រលើកទឹកចិត្តដល់មនុស្សតែម្នាក់ប៉ុណ្ណោះ នោះគឺជាការគ្រប់គ្រាន់ហើយ។ ឧទាហរណ៍ : ក្មេងម្នាក់ត្រូវគេបោះបង់ចោល យុវជនម្នាក់គ្មានការងារធ្វើ និងបាត់សេចក្តីសង្ឃឹម មនុស្សម្នាក់ត្រូវគេបៀតបៀនមើលងាយ ឬមនុស្សចាស់ជរាជាដើម។

ចូរជ្រើសរើសយកសេចក្តីស្រឡាញ់ ! ចូរជ្រើសរើសយកសេចក្តីសង្ឃឹម !

ព្រះជាម្ចាស់បានជ្រើសរើសយើងម្នាក់ៗរួចស្រេចហើយ : “កុំខ្លាចអី ! យើងបានហៅអ្នកតាមឈ្មោះរបស់អ្នក ហើយអ្នកគឺជាកម្មសិទ្ធិរបស់យើង ហើយយើងជាព្រះរបស់អ្នក អ្នកមានតម្លៃថ្លៃថ្នូរបំផុត។ យើងស្រឡាញ់អ្នក”។ នៅក្នុងការអធិដ្ឋាន យើងបានបន្ទាបខ្លួន រួមជាមួយអស់អ្នកដែលមានការជឿទុកចិត្តមកលើយើង នៅក្រោមព្រះហឫទ័យប្រណីសណ្តោសរបស់ព្រះជាម្ចាស់។ ព្រះអង្គទទួលយើងតាមគ្រប់លក្ខណៈរបស់យើងទាំងអស់ ទាំងសេចក្តីល្អទាំងគ្រប់ការប្រទាញប្រទង់ដែលមាននៅក្នុងដួងចិត្តរបស់យើង ព្រមទាំងកំហុសរបស់យើងផងដែរ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានលើកទឹកចិត្តយើង។ “ភាពទន់ខ្សោយរបស់យើង គឺជាទ្វារឱ្យព្រះវិញ្ញាណដ៏វិសុទ្ធចូលទៅគង់ក្នុងជីវិតរបស់យើង”។

# ពិធីទទួលស្វាគមន៍យុវនារី ២រូប ជានូវីស

នៅថ្ងៃទី៤ ឧសភា ឆ្នាំ២០០៧ ក្រុមបងស្រីឧបការគុណបានជួបជុំគ្នានៅមណ្ឌលរបស់ពួកគាត់នៅភ្នំពេញ ដើម្បីប្រារព្ធបុណ្យរំឭកថ្ងៃមរណភាពរបស់លោកយ៉ូហានម៉ាក់ តេម៉ល ជាអ្នកបង្កើតក្រុមឧបការគុណនេះ។ នៅថ្ងៃនោះដែរ ក៏មានរៀបចំពិធីទទួលស្វាគមន៍បងស្រីថ្មី ២នាក់ គឺបងស្រីអាណា ម៉ារី ខាយដានី និងម៉ារី ម៉ាដាឡា ខិនចន្ថា ចូលជានូវីសនៃក្រុមបងស្រីឧបការ-គុណ។ ក្នុងកម្មវិធី ក៏បានការចូលរួមពីលោកអភិបាលអេមីល ដេតម្បលោកអភិបាលអង់តូនី និងលោកបូជាចារ្យជាច្រើនរូបទៀតផង។



Photo: H. Rann

ក្នុងទឹកមុខរីករាយ បងស្រីប្រធានក្រុមឧបការគុណអាញ៉េស សម្តែងអារម្មណ៍ថា : “នេះជាសេចក្តីសង្ឃឹមសម្រាប់ខ្ញុំ និងក្រុមគ្រួសារយើងនៅប្រទេសកម្ពុជា ដែលចាប់តាំងពីសង្គ្រាមនៅឆ្នាំ១៩៧៥មក នេះជាលើកដំបូងហើយ ដែលមានប្អូនស្រីពីរនាក់ចូលក្រុមគ្រួសារយើង”។ ក្រុមបងស្រីឧបការគុណនៅប្រទេសកម្ពុជា មានសមាជិក ១៤នាក់ និងសមាជិកថ្មីពីរនាក់ ហើយមានម្នាក់ទៀតកំពុងសិក្សាស្វែងយល់។ បងស្រីម៉ារីម៉ាដាឡា ខិនចន្ថា មានប្រសាសន៍ថា : “ខ្ញុំមានអំណរសប្បាយ និងមានសុភមង្គលណាស់ពេលនេះ។ ខ្ញុំមានមោទនភាព ដែលបានឆ្លងកាត់ឧបសគ្គ និងឈានមួយជំហានទៀតដើម្បីដើរតាមព្រះអង្គដែលខ្ញុំបានសម្រេចចិត្ត”។ ចំណែកបងស្រីអាណាម៉ារីខាយ ដានី ពោលថា គាត់មិនស្មានថា មានថ្ងៃនេះពិតប្រាកដទេ ធ្វើឱ្យគាត់មានអំណរសប្បាយរីករាយណាស់។

ហ៊ិន វ៉ាន់

# ចូលឆ្នាំ : ព្រះសហគមន៍សន្តយ៉ូសែបចែកអំណោយ

កាលពីព្រឹកថ្ងៃអង្គារ ទី១០ ខែមេសា ឆ្នាំ២០០៧ កន្លងទៅនេះ។ ព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច) បានរៀបចំពិធីចែកអំណោយដល់គ្រួសារក្រីក្រចំនួនប្រមាណជា ១០០គ្រួសារ។

ក្នុងពិធីនោះ គឺមានការអញ្ជើញចូលរួមពីសំណាក់លោកឪពុកបប់ លោកឪពុកឆាតឆ័យ តំណាងចៅសង្កាត់ទួលសង្កែ ព្រមទាំងតំណាងគណៈកម្មការរបស់ព្រះសហគមន៍ និងបងប្អូនក្រីក្រចំនួន ១០០ គ្រួសារផងដែរ។ មានប្រសាសន៍ នៅក្នុងឱកាសនោះ លោកឪពុកបប់ ក៏ធ្វើការចាប់អារម្មណ៍ថា : ““នៅថ្ងៃនេះ ខ្ញុំមានអំណរសប្បាយរីករាយជាខ្លាំងដែលបងប្អូន អញ្ជើញមកដល់ទីនេះ។ ជីវិតយើងម្នាក់ៗ ត្រូវមានអំណរសប្បាយ និងរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ទោះបីយើងជាអ្នកក្រីក្រ តែយើងមានទំនាក់ទំនងល្អ ជាមួយគ្នា និងចេះជួយគ្នាទៅវិញទៅមក។ អំណោយដែលត្រូវចែកជូនបងប្អូននៅពេលនេះ ថ្វីត្បិតតិចតួចក្តី តែវាគឺជាអំណរសប្បាយដែលស្តែងចេញឱ្យឃើញថា យើងចេះចែករំលែកឱ្យគ្នាទៅវិញទៅមក។

តំណាងចៅសង្កាត់ទួសសង្កែ មានប្រសាសន៍ថា : “ក្នុងនាមខ្ញុំជាតំណាងចៅសង្កាត់ និងក្នុងនាមបងប្អូនក្រីក្រទាំង ១០០គ្រួសារ សូមថ្លែងអំណរគុណចំពោះលោកឪពុក និងព្រះសហគមន៍ ដែលរៀបចំចែកអំណោយនេះ។ សូមគោរពជូនពរឱ្យលោកមានសុខភាពល្អនៅក្នុងឱកាសឆ្នាំថ្មីនេះ។

ឡុង សម្ជួសៀ



Photo: L. Samphors

# លោកអេមីលដេតម្បជួបសម្តេចសង្ឃរាជទេពវង្ស

កាលពីថ្ងៃបុណ្យវិសាខបូជា មានជំនួបមួយរវាងសម្តេចព្រះសង្ឃរាជទេព វង្ស និងលោកអភិបាលភូមិភាគភ្នំពេញ។ លោកអភិបាលមានប្រសាសន៍ថា លោក និងសម្តេចព្រះអគ្គមហាសង្ឃ បានលើកឡើងអំពីទំនាក់ទំនងរវាងព្រះសហគមន៍កាតូលិក និងសាសនាដទៃៗ។ ចំណែកសម្តេចទេព វង្ស មានសង្ឃដីកាថា ព្រះអង្គជ្រាបច្បាស់ថា ព្រះសហគមន៍គឺតែងជួយអ្នកក្រីក្រដោយមិនប្រកាន់។

## អេម៉ានូអែល

សម្លេងពីព្រះសហគមន៍កាតូលិក !



ភ្នំពេញ : FM 99.5 Mhz

ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍។

បាត់ដំបង : FM 91.0 Mhz

ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

កំពង់ធំ : FM 107.3 Mhz

ម៉ោង ៥:៣០-៦:០០ រាល់ល្ងាចថ្ងៃសៅរ៍។

កំពង់ចាម : FM 100.5 Mhz

ម៉ោង ៩:៣០-១០:០០ យប់ថ្ងៃអាទិត្យ។





# លទ្ធផលផ្លូវការ នៃការបោះឆ្នោត ឃុំ-សង្កាត់ អាណត្តិទី២

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហៅកាត់ថា គ.ជ.ប ប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ នៅទូទាំងប្រទេស កាលពីថ្ងៃទី២៤ មេសា ឆ្នាំ២០០៧។ មានគណបក្សនយោបាយចំនួន ០៥ បានទទួលអាសនៈ :

គណបក្សប្រជាជនកម្ពុជា ទទួលធ្វើមេឃុំ-ចៅសង្កាត់ចំនួន ១ ៥៩១ រូប ជំទប់ទីមួយ ១ ១២៥ រូប ជំទប់ទីពីរ ១៨៥ រូប និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួន ៥ ០៩២ រូប ដែលសរុបចំនួន ៧ ៩៩៣ រូប។

គណបក្សសម រង្ស៊ី ទទួលបានមេឃុំ-ចៅសង្កាត់ចំនួន ២៨ រូប ជំទប់ទីមួយ ៤០៣ រូប ជំទប់ទីពីរ ៩៦៣ រូប និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួន ១២៦៦ រូប ដែលសរុបមានចំនួន ២ ៦៦០ រូប។

គណបក្សហ្វ៊ុនស៊ិនប៉ិច បានទទួលមេឃុំ-ចៅសង្កាត់ ចំនួន ២ រូប ជំទប់ទីមួយ ៤៧ រូប ជំទប់ទីពីរ ១៥៥ រូប និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួន ៧០ រូប ដែលសរុបមានចំនួន ២៧៤ រូប។

គណបក្សនរោត្តម រណឫទ្ធិ បានទទួលជំទប់ទីមួយចំនួន ៤៦ រូប ជំទប់ទីពីរ ៣១៧ រូប និងសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ៦២ រូប សរុបចំនួន ៤២៥ រូប។

គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ បានទទួលជំទប់ទីពីរ ចំនួន ១ រូប។

សរុបសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ មានចំនួន ១១ ៣៥៣ នាក់ ដែលត្រូវនឹងចំនួនឃុំ-សង្កាត់ទាំងអស់ ១ ៦២១ ឃុំ-សង្កាត់ នៅទូទាំងប្រទេសកម្ពុជា។




Photo: Khem Sovannara

## ជំនួប

# សហភាព ភូមា




Photo: WORL MISSION

ប្រទេសអង់គ្លេសបានវាយដណ្តើមគ្រប់គ្រងប្រទេសភូមាអស់រយៈជាង ៦២ឆ្នាំ (១៨២៤-១៨៨៦) និងបានបញ្ចូលទឹកដីនេះទៅក្នុងចក្រភពឥណ្ឌា។ ភូមាត្រូវបានចាត់ទុកជាខេត្តមួយរបស់ឥណ្ឌារហូតដល់ឆ្នាំ ១៩៣៧ ទើបមានការផ្តាច់ខ្លួនគ្រប់គ្រងដោយខ្លួនឯង។ តែភូមាទទួលឯករាជ្យពីចក្រភពអង់គ្លេសនៅឆ្នាំ១៩៤៨។

លោកហ្សេន ណេវីន បានគ្រប់គ្រងរដ្ឋាភិបាលដោយយោធា និងតែងតាំងខ្លួនឯងជាប្រធានាធិបតី និងក្រោយមកក្លាយជាអ្នកនយោបាយដ៏សំខាន់ចាប់ពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៨៨។ នៅឆ្នាំ ១៩៩០ មានការបោះឆ្នោតសេរី និងមានគណបក្សជាច្រើនចូលរួម។ នៅពេលនោះ លទ្ធផលឈ្នះដ៏លើសលុបបានទៅលើគណបក្សប្រឆាំង ដែលហៅថា សហព័ន្ធជាតិដើម្បីលទ្ធិប្រជាធិបតេយ្យ និងដឹកនាំដោយអ្នកស្រី អ៊ុង សាន ស៊ូជី តែពួកអ្នកនីតិបញ្ញត្តិ ដែលកំពុងគ្រប់គ្រងរដ្ឋ [illegible]

ឯកសារបរទេស

### ទិន្នន័យផ្សេងៗ

ឈ្មោះផ្លូវការ : សហភាពមីយ៉ានម៉ា។ ប្រជាពលរដ្ឋ : ៤៧ ៣៨២ ៦៣៣ នាក់។ ជនជាតិ : ភូម៉ា ៦៨ ٪ សាន ៩ ٪ ការ៉ែន ៧ ٪ រ៉ាគិន ៤ ٪ ចិន ៣ ٪ ឥណ្ឌា ២ ٪ ម៉ន ២ ٪ និងជាតិសាសន៍ដទៃៗទៀត ៥ ٪។ ភាសា : ភូមា និងភាសាជនជាតិកុលសម្ព័ន្ធ ឬជនជាតិភាគតិច។ សាសនា : ព្រះពុទ្ធ ៨៩ ٪ គ្រីស្ត ៤ ٪ ម៉ូស្លីម ៤ ٪ និងដទៃទៀត ៣ ٪។ ផ្ទៃដី : ៦៧៨ ៥០០ គម$^2$។ ធនធានធម្មជាតិ : ប្រេងកាត ព្រៃឈើ សំណ សំណប៉ាហាំង ស័ង្កសី ទង់ដែង ស្ពាន់ធ័រ ថ្មកែវ ថ្មកំបោរ ត្បូងមានតម្លៃ និងឧស្ម័នធម្មជាតិ។ របបគ្រប់គ្រងរដ្ឋ : គ្រប់គ្រងដោយយោធា។ រូបិយវត្ថុ : គីយ៉ាត។ ឯករាជ្យភាព : ថ្ងៃ៤ មករា ឆ្នាំ១៩៤៨ ចំណែកថ្ងៃបង្កើតសហភាពមីយ៉ានម៉ា គឺនៅថ្ងៃ១២ កុម្ភៈ ឆ្នាំ១៩៤៧។

សីលធម៌ជាការប្រតិបត្តិមួយដ៏សំខាន់ ដែលមនុស្សម្នាក់ៗត្រូវតែមានជាពិសេស ចំពោះយុវវ័យ ហើយប្រទេសជាតិមួយអាចរីកចម្រើនទៅបាន ក៏អាស្រ័យដោយប្រជាពលរដ្ឋនៃប្រទេសនោះមានសីលធម៌ល្អផងដែរ។ ម្យ៉ាង ដោយមានការហូរចូលនូវវប្បធម៌បរទេសស្ទើរគ្រប់ជ្រុងជ្រោយ និងជ្រៀតជ្រែកជ្រុលមកក្នុងខួរក្បាល និងស្មារតីរបស់យុវវ័យក្នុងសង្គមខ្មែរ នេះជាហេតុនាំឱ្យសីលធម៌របស់ពួកគេមានការធ្លាក់ចុះគួរឱ្យព្រួយបារម្ភ។

តើយុវវ័យសម័យនេះមានការប្រែប្រួល និងខុសប្លែកពីសម័យមុនដូចម្តេចខ្លះ? តើគួរអប់រំ និងណែនាំពួកគេយ៉ាងដូចម្តេចដើម្បីឱ្យពួកគេដើរតាមផ្លូវល្អ និងត្រឹមត្រូវនៅក្នុងសង្គមជាតិ និងគ្រួសារ?

# ទស្សនៈផ្សេងៗ ចំពោះសីលធម៌យុវវ័យ



ការសម្លុតទារលុយក្មេងតូចៗរបស់យុវជនហៅបងធំ គឺទង្វើអសីលធម៌

Photo: DR



Photo: P. Samphy

យុវជនដែលសម្លឹងទៅរកអនាគតដោយការខិតខំសិក្សានាបច្ចុប្បន្ន និងលះបង់ចោលនូវអំពើអបាយមុខនឹងទទួលបានលទ្ធផលល្អសមជាពលរដ្ឋនៃប្រទេសដែលមានអរិយធម៌

ជារឿយៗ នៅតាមកញ្ចក់ទូរទស្សន៍ វិទ្យុ និងទំព័រសារពត៌-មានជាច្រើន តែងមានការផ្សព្វផ្សាយទាក់ទងទៅនឹងបញ្ហាសីលធម៌ និងសុជីវធម៌ ផ្តោតសំខាន់ទៅលើយុវវ័យ ទាំងនៅក្នុងសាលា វត្តអារាម ទីសាធារណៈ និងគេហដ្ឋានជាដើម។ ឈុតឆាកផ្សព្វផ្សាយនោះភាគច្រើន គឺគេឃើញមានសម្តែងដោយយុវវ័យទាំងប្រុស-ទាំងស្រី។

លោកផុន វីន បុគ្គលិកក្លឹបហាត់ប្រាណមួយកន្លែងនៅទីក្រុងភ្នំពេញ ហាក់ដូចជាខឹងសម្បាជាមួយនឹងអាកប្បកិរិយា មិនគប្បីរបស់យុវវ័យមួយចំនួន ដែលធ្វើខុសឆ្គង និងធ្វើឱ្យអាប់អោនសីលធម៌របស់ប្រជាជនខ្មែរ ដែលធ្លាប់ល្បីល្បាញកាលពីសម័យមុន។ លោកមានប្រសាសន៍ថា: “នាសម័យនេះ បើយើងនិយាយពីសីលធម៌វិញ គឺមានការចុះទាបឆ្ងាយណាស់ បើប្រៀបធៀបទៅនឹងសម័យដែលខ្ញុំនៅរៀន ក៏ដូចជាពេលដែលខ្ញុំនៅជាយុវជននោះ។” លោកបញ្ជាក់ថា សម័យនេះគឺខុសប្លែកគ្នាផ្ទុយស្រឡះពីសម័យមុនៗ ដោយសារ ពេលមុនយុវវ័យឃើញចាស់ៗ ពួកគេចេះដើរឱនលំទោន ជម្រាបសួរនិងចេះប្រាប់ឪពុកម្តាយថា ពួកគេត្រលប់មកពីសាលារៀនវិញហើយ តែក្មេងៗសម័យឥឡូវនេះខ្លះ មិនធ្វើដូច្នេះទៀតឡើយ។ លោកវីន និយាយបន្តក្នុងសម្លេងខ្លាំងៗថា សម្រាប់បុរសខ្មែរយើងសព្វថ្ងៃវិញ ពួកគេខ្លះ ភ្លេចសីលធម៌របស់ខ្លួនយ៉ាងច្រើន និងភ្លើតភ្លើនច្រើនហួសកម្រិត។

កំពុងបោចស្មៅនៅខាងមុខសារមន្ទីរជាតិ អ្នកស្រីអ៊ឹង ស៊ីផុន ជាអ្នកថែសួននៅមុខសារមន្ទីរជាតិ បានឱ្យដឹងថា ថ្ងៃខ្លះគាត់មានការភិតភ័យចំពោះកាយវិការមិនស្តាប់បង្គាប់គាត់របស់មនុស្សម្នា ដែលពួកគាត់បានប្រាប់មិនឱ្យពួកគេដើរជាន់ស្មៅ ឬបោះចោលសំរាមនៅក្រៅធុងផ្តេសផ្តាស។ គាត់បន្តឱ្យដឹងទៀតថា: “អ្នកខ្លះគេចេះគោរព សីលធម៌ អ្នកខ្លះមិនគោរព ភ្លើតភ្លើន ផឹកស៊ី និងដើរពង្រាយសំរាមចោលពាសពេញដី។ តែមានអ្នកភាគតិចណាស់ ដែលញ៉ាំអ្វីហើយ ពួកគេចេះយកសំរាមទៅបោះចោលនៅក្នុងធុងត្រឹមត្រូវនោះ។ ជួនកាលខ្ញុំប្រាប់គេល្អៗ ប៉ុន្តែពួកគេបែរជាជេរ និងប្រើនូវពាក្យផ្សេងៗស្តីយ៉ាងអសុរោះមកកាន់ខ្ញុំវិញ។”

នៅជ្រុងម្ខាងនៃព្រះបរមរាជវាំង ពីមុន មានបើកឱ្យសិស្ស-និស្សិត និងប្រជាពលរដ្ឋធ្វើដំណើរឆ្លងកាត់ដោយសេរី ប៉ុន្តែបន្ទាប់ពីមានការធ្វើឱ្យខូចសណ្តាប់ធ្នាប់ខ្លះៗមក ដូចជាមានចោលសំរាម បង្ហោះម៉ូតូ ផឹកស៊ី និងពេលខ្លះ មានដេញកាប់វាយតប់គ្នាទៀត។ ដោយមើលឃើញបញ្ហាធ្ងន់ធ្ងរបែបនេះកន្លែងនោះបានបិទមិនឱ្យមានធ្វើដំណើរបន្តទៀតទៅ។

លោកញាណ ចក់មន ជាមន្ត្រីប៉ូលីសការពារព្រះបរមរាជវាំង និងកំពុងអង្គុយក្បែរម៉ូតូ ដោយមានកូនវិទ្យុ១សម្រាប់ស្តាប់កំដរអារម្មណ៍។ លោកដែលមានភារកិច្ចយាមកាមកុំឱ្យមានក្មេងស្ទាវឆ្លងកាត់ទីនោះ បានងាកមកប្រាប់អ្នកយកពត៌មានយើង អំពីការយល់ឃើញរបស់លោក ចំពោះបញ្ហាសីលធម៌ និងការភ្លើតភ្លើនរបស់យុវវ័យសម័យថ្មីនេះថា: “ខ្ញុំយល់ថា យុវវ័យសម័យនេះ មានការខុសប្លែកគ្នាពីសម័យមុន ឃើញថា ពួកគេភ្លើតភ្លើន ក្លាហាន និងមិនចេះគោរពសណ្តាប់ធ្នាប់ដូចជាពុំគោរពច្បាប់ចរាចរណ៍ជាដើម។ ពួកគេមានភាពទាន់សម័យ បណ្តាលឱ្យភ្លេចអរិយធម៌ និងសីលធម៌ខ្មែរពីជំនាន់ដើម។” លោកបន្តថា កត្តាទាំងនោះអាចបណ្តាលមកពីមានការហូរចូល និងការសេពគ្រឿងញៀន-ល-។ សម័យដើម និងបច្ចុប្បន្ននេះមានលក្ខណៈខុសគ្នាឆ្ងាយ។ នៅសម័យមុន នៅពេលដែលពួកគាត់ឃើញចាស់ព្រឹទ្ធាចារ្យ គឺពួកគាត់តែងគោរពឱ្យនលំទោន តែនៅពេលនេះ គឺវាផ្ទុយស្រឡះតែម្តង ដោយនៅពេលយុវជនខ្លះ ដើរទៅឃើញចាស់ទុំ ឬព្រះសង្ឃ គឺមិនគោរព និងមិនដោះមួកជាដើម។ យុវវ័យពីសម័យមុន គ្រាន់តែដើរកាត់តាមវត្តអារាម ក៏គេដោះមួកដែរ។ ចំពោះការអប់រំទូន្មានប្រៀនប្រដៅកូនៗ ដែលកំពុងឈានចូលទៅក្នុងស្រទាប់យុវវ័យដែរនោះ លោកញាណ ចក់មន ក៏បានឱ្យដឹងថា សម្រាប់កូនៗគាត់ផ្ទាល់ គាត់ធ្វើការអប់រំ និងមិនឱ្យពួកគេភ្លើតភ្លើនតាមសង្គម ឬសម័យជឿនលឿនពេកទេ គឺពួកគេត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ឱ្យបានជាប់លាប់ដើម្បីឈានទៅរកអនាគតរបស់ខ្លួន។ បើបណ្តែតបណ្តោយឱ្យកូនភ្លើតភ្លើនទៅតាមសង្គម គឺវាធ្វើឱ្យខ្លួនឯង និងសង្គមកាន់តែធ្លាក់ចុះ និងកាន់តែយ៉ាប់។ “ខ្ញុំក៏ធ្វើការប្រដៅអប់រំបង្រៀនពួកគេឱ្យមាននូវសីលធម៌ និងចេះគោរពចាស់ទុំ ឪពុកម្តាយដើម្បីអនាគតខ្លួននៅពេលអនាគត។” នេះជាទង្វើដែលមន្ត្រីប៉ូលីសរូបនេះបានធ្វើចំពោះកូនរបស់គាត់។

ជាមួយគ្នានេះដែរ លោកអេមីល ដេតម្ប អភិបាលភូមិភាគភ្នំពេញ ក៏មានប្រសាសន៍ចាប់អារម្មណ៍នឹងបញ្ហាយុវវ័យដែរថា: “យុវវ័យជាអនាគតរបស់ប្រទេសកម្ពុជា ហើយនៅក្នុងព្រះសហគមន៍ យុវជនជាអនាគតរបស់ព្រះសហគមន៍ ប៉ុន្តែចំពោះខ្ញុំពួកគេមិនគ្រាន់តែជាអនាគតតែប៉ុណ្ណោះទេ។ យុវ-ជនជាមនុស្សពេញលក្ខណៈតាមរបៀបជាយុវវ័យ ដែលនេះគឺជាអ្វីដែលសំខាន់។ ដូច្នេះយើងត្រូវយកចិត្តទុកដាក់ចំពោះក្មេងៗជាដំបូង ក្រោយមកគឺយុវវ័យនិងមនុស្សពេញវ័យ។” លោកផ្តោតអារម្មណ៍សំខាន់ចំពោះយុវវ័យនៅក្នុងព្រះសហ-គមន៍ថា លោកប្រឆាំងចំពោះឃ្លាដែលពោលថា យុវវ័យជាអនាគតរបស់ព្រះសហគមន៍ គឺមិនមែនទេ សម្រាប់លោក។ យុវវ័យពុំមែនជាអនាគតព្រះសហគមន៍ទេ តែជា“បច្ចុប្បន្ន” របស់ព្រះសហគមន៍ មានន័យថា យុវវ័យមានកន្លែងពិសេសនៅក្នុងព្រះសហគមន៍ គេមិនរង់ចាំដល់គេពេញវ័យនោះទេ គឺគេមានមុខងារដ៏សំខាន់ក្នុងការជួបជុំគ្នា រួបរួមគ្នា និងអប់រំគ្នាដើម្បីរៀបចំអនាគត។

យុវជនលី ជា និស្សិតច្បាប់ និងកំពុងតែស្ថិតនៅក្នុងស្រទាប់យុវវ័យម្នាក់ដែរនោះ តើគាត់មានទស្សនៈយ៉ាងណាចំពោះយុវវ័យសម័យនេះដែរ? ...

## អ្នកជិតខាង

អ្នកថ្លៃថ្នូរត្រូវមានសេចក្តីសុខជាមួយអ្នកជិតខាង ព្រោះអ្នកទាំងនោះ ជាបងប្អូន ជួយឈឺឆ្អាលយើងដូចបងប្អូនបង្កើតរបស់យើងដែរ។ យើងមិនត្រូវរាប់អានអ្នកនៅខាងមុខផ្ទះ ស្អប់អ្នកនៅសងខាង ឬអ្នកនៅខាងក្រោយផ្ទះទេ។ ទោះបីយើងជាអ្នកមានយ៉ាងណាក្តី បើគ្មានការគាំទ្រពីអ្នកជិតខាង យើងក៏គ្មានសេចក្តីសុខដែរ។

…“ចំពោះខ្ញុំ នៅពេលជួបជាមួយចាស់ទុំជាដំបូង គឺជម្រាបសួរ បន្ទាប់មកសួរថា អ៊ំ ឬពូទៅណាដែរ? សុខសប្បាយជាទេ? ជាដើម។” នេះជាកាយវិការដែលយុវជនលី បានប្រតិបត្តិជាប្រចាំនៅពេលគាត់ជួបជាមួយចាស់ទុំ ឬក៏អ្នកដែលមានវ័យចាស់ជាងខ្លួន។ ទង្វើនេះ លោកបានធ្លាប់ឃើញមានយុវវ័យមួយចំនួនប្រព្រឹត្តដូចលោកដែរ តែក៏មានមួយចំនួនមិនមានសីលធម៌ត្រឹមត្រូវ និងនិយាយមិនល្អជាមួយគេដែរ។

ចំពោះបញ្ហាដែលថា ប្រសិនប្រទេសជាតិមួយពោរពេញទៅដោយយុវវ័យដែលខ្វះសីលធម៌ តើនឹងមានអ្វីកើតឡើង? យុវនិស្សិតច្បាប់ឆ្នាំទី២ រូបនេះ បញ្ចេញទស្សនៈថា នេះគឺជាកត្តាមួយសំខាន់ ពីព្រោះប្រទេសមួយពឹងលើយុវវ័យ ដែលជាទំពាំងស្នងឫស្សី ដូច្នេះបើយុវវ័យមិនខិតខំរៀនសូត្រនោះប្រទេសជាតិនឹងមិនរីកចម្រើនទេ មិនតែប៉ុណ្ណោះ វាកាន់តែធ្លាក់ចុះដុនដាបទៅទៀត។ “ក្នុងនាមជាយុវជន ខ្ញុំព្យាយាមធ្វើ និងប្រាប់ដល់អ្នកឯទៀតៗ ផងដែរថា អ្នកគួរខិតខំរៀនសូត្រ កុំបណ្តោយខ្លួនឱ្យធ្លាក់ទៅក្នុងភាពមហន្តរាយពីព្រោះយើងជា ទំពាំងស្នងឫស្សី ឬជាសសរទ្រូងរបស់ប្រទេសជាតិដែលត្រូវជួយលើកស្ទួយប្រទេសជាតិខ្លួនឱ្យរីកចម្រើនដូចជាអរិយប្រទេសនានាលើសកលលោក។”

ការប្រៀនប្រដៅ ការអប់រំកូនៗ ឱ្យក្លាយទៅជាយុវជន និងយុវតីគំរូមួយរូបនៅក្នុងសង្គម វាមិនមែនជាបញ្ហាមួយដែលពិបាកនោះទេ ប៉ុន្តែវាអាស្រ័យទៅលើវិធីសាស្ត្រណែនាំ និងទូន្មានពួកគេដោយសមរម្យតែប៉ុណ្ណោះ។

ចំណែកលោកអភិបាល អេមីល ដេតម្ប បានឱ្យដឹងអំពីចំនុចនេះថា អ្វីដែលបង្ខំ គឺគ្មានប្រយោជន៍នោះទេ។ ក្នុងនោះដែរយើងត្រូវមានការប្រុងប្រយ័ត្នក្នុងការប្រៀនប្រដៅដល់ពួកគេ ដោយច្រើនតែប្រើពាក្យថា កុំធ្វើនេះ! កុំធ្វើនោះ! ច្រើនពេក។ លោកសង្កត់ធ្ងន់បន្ថែមពីលើបញ្ហានេះ សម្រាប់ឪពុកម្តាយទៀតថា: “មុខងាររបស់ឪពុកម្តាយ គឺជាអ្នកអប់រំដល់កូនចៅ”។ ការអប់រំល្អមិនមែនផ្អែកតែទៅលើការវាយតប់បង្ខំកូននោះទេ ប៉ុន្តែគួរតែនិយាយប្រាប់កូនអំពីមូលហេតុនៃទង្វើពួកគេវិញថា តើទង្វើនោះ នឹងផ្តល់ផលអ្វីខ្លះចំពោះពួកគេ តើវាឱ្យផលល្អ ឬអាក្រក់? ពុំមែនកូនធ្វើខុសអ្វីមួយ ត្រូវដាក់ទោសគេភ្លាមៗនោះទេ ប៉ុន្តែអ្វីដែលសំខាន់នោះ ត្រូវធ្វើការសាកសួរ និងធ្វើការពន្យល់ដល់កូន។ យើងត្រូវប្រាប់ឱ្យពួកគេចេះសម្តែងចេញនូវសេចក្តីស្រលាញ់ ការយោគយល់ និងចេះយកអាសាអ្នកដទៃនៅជុំវិញខ្លួន។

អត្ថបទដោយមុំ គន្ធា

**យុវសិស្សលី**

“ខ្ញុំគិតថា ចំពោះកម្មវិធីអប់រំនៅតាមវិទ្យុ និងទូរទស្សន៍ គឺអាចទទួលយកបាន។ ប៉ុន្តែប្រសិនបើគ្មានការជួយជំរុញ និងអប់រំបន្ថែមពីឪពុកម្តាយទេនោះ។ ពួកគេនៅតែប្រព្រឹត្តខុសរហូតពីព្រោះតាមពិត ពួកគេមិនសូវជាបានមើលកម្មវិធីអប់រំនោះប៉ុន្មានទេ ដោយបែរជាទៅមើលបាល់ទាត់ ឬរឿងផ្សេងៗជាដើម។ បើឪពុកម្តាយមានភាពតឹងរ៉ឹង ឧស្សាហ៍ធ្វើការពន្យល់ណែនាំនោះស្ថានភាពនឹងប្រសើរ”។

# ដំណើរជីវិត

ផ្ទាំងជីវិត គឺជាជញ្ជាំងផ្ទះមួយដែលគ្មានដំបូល ហើយគ្មានកម្ពស់ពិតប្រាកដផង។ មនុស្សម្នាក់ៗប្រៀបបាននឹងជាងសង់ផ្ទះដែលរៀបជញ្ជាំងក្នុងមួយថ្ងៃឥដ្ឋមួយដុំ។ ជីវិតចេះតែធ្វើដំណើរទៅមុខ រីឯជញ្ជាំងផ្ទះចេះតែខ្ពស់ឡើងទៅលើដែរ។ នៅពេលដែលគេឡើងទៅដល់ខ្ពស់ ទើបមនសិការសីលធម៌ និងការចេះដឹងរបស់គេ បើកទស្សនៈវិស័យទៅរកទុទិដ្ឋិនិយម ឬសុទិដ្ឋិនិយមទៅតាមទស្សនៈរៀងៗខ្លួន។

កាលបើគេត្រាច់ចរតាមស្នាមដានជីវិតដល់កំផែងខ្ពស់ហើយ គេមិនត្រូវសំងំក្រាបក្បាលយកសុខតែម្នាក់ឯង ធ្វើគរ ធ្វើថ្លង់ បិទប្រស្រីភ្នែកមិនសម្លឹងមកមើលអ្វីៗដែលនៅខាងក្រោមនោះទេ។ ការពិសោធន៍ដ៏យូរអង្វែងតាមស្នាមជីពជុល ប៉ះពាំទួលើគន្លងផ្ទាំងជីវិត បានធ្វើឱ្យមនុស្សមានស្មារតីរឹងប៉ឹង មោះមុត តស៊ូ និងមានសេចក្តីក្លាហាន។

នៅពេលឡើងដល់ទីខ្ពស់នោះ គេនឹងងាកមកក្រោមឃើញឈូងសមុទ្រកម្សៀវ កោះសប្បាយ ភ្នំភ្លើងនៃជម្លោះ ចាក់ដោត ទីវាលវិយោគ សោកសង្រេង គុម្ពោតព្រៃសុទ្ធសាធ ព្រៃស្បាតបន្លាមួយហ្វូង ត្រពាំងទឹកភ្នែក ហើយនិងថ្លុកនៃការស្តាយក្រោយ-ល-។ កាលបើគេឡើងឱ្យកាន់តែខ្ពស់ៗជាងនេះទៅទៀតនោះ គេនឹងចោលនេត្រាបានឆ្ងាយជាងនេះទៅទៀត ហើយគេនឹងឃើញភ្នំធំៗដែលស្ថិតនៅឯនាយឆ្ងាយសន្លឹម មានជួរវែងៗជាប់គ្នា ដែលនៅពីក្រោយភ្នំនោះ គេនឹងឃើញមានអាថ៌កំបាំងដ៏គួរឱ្យព្រឺក្បាលជាក់ជាមិនខានឡើយ។

តើយើងធ្វើដូចម្តេចទើបអាចមើលឃើញនូវអាថ៌កំបាំងនៅខាងក្រោយភ្នំទាំងនោះទៅ? តើនរណាអាចឆ្លើយត្រូវថា អាថ៌កំបាំងទាំងនោះមានអ្វីខ្លះ? តើជួរភ្នំព្រំប្រទល់ដែនផ្អែកនោះមានឈ្មោះជាអ្វីទៅវិញ? កាលបើមិនមាននរណាដឹង ឬការដឹងនោះមិនសូវមានតម្លៃសម្រាប់យើង នាទីសុជីវធម៌របស់យើងតម្រូវឱ្យយើងមានការរង់ចាំ។ ជញ្ជាំងរបស់យើងផ្ទាល់ត្រូវបានសង់ដល់កម្ពស់ ដែលមិនអាចមើលឃើញ ហើយថាត្រូវពិតប្រាកដនោះចុះ។ ត្រដោកកម្មដែលព្យួរជាប់នៅនឹងកមនុស្សគ្រប់រូប ជួនក៏ជំរុញឱ្យសង់ជញ្ជាំងបានខ្ពស់ ជួនក៏សង់បានទាប ហើយទីបំផុតក្រោលផ្នូកជីវិតរបស់យើងមិនដឹងនៅទីណា រួចបានចុចកណ្តឹងរោទិ៍ហៅឱ្យជីវិតវិលទៅទីនោះវិញ ដោយទុកឱ្យរូបកាយទៅជាចំណីនៃអគ្គី ឬសត្វធាតុនានា។ តើអ្វីទៅជាជីវិតនេះ?

សំរង់ពីសៀវភៅសុជីវធម៌





**នៅសាលាដុនបូស្កូទឹកថ្លា នាថ្ងៃទី២៦ មេសា ២០០៧កន្លងទៅនេះ មានធ្វើពិធីសម្ពោធអគារមត្តេយ្យ និងបឋមសិក្សា ដែលមានជាង ២០ បន្ទប់ ក្រោមអធិបតីភាពព្រះអម្ចាស់ក្សត្រីស៊ីសុវត្ថិពង្សនារី មុនីពង្ស និងភ្ញៀវជាច្រើនរូបទៀត។**

# អគារថ្មីនាំមកនូវក្តីសង្ឃឹមថ្មី


ការអប់រំដែលល្អគឺចាប់ផ្តើមពីកុមារតូចៗ

Photo: S. Philong

ពិធីគោរពទង់ជាតិ និងរាំរបាំជូនពររបស់សិស្សសាលាបឋមសិក្សាបានបញ្ចប់ តំណាងសិស្សនៃសាលាដុនបូស្កូទឹកថ្លាបានឡើងថ្លែងសុន្ទរកថាស្វាគមន៍ និងអរគុណចំពោះម្ចាស់ជំនួយ និងភ្ញៀវចូលរួមទាំងអស់ ប្រមាណជា ៣០០នាក់។

កុមារីសុជាតា បាននិយាយថា កន្លែងនេះជាកន្លែងមួយដែលមានតម្លៃ និងជាកន្លែងអប់រំមួយដ៏ពេញលេញបំផុតនាពេលអនាគត។ សុជាតាបន្តដែរថា យើងទាំងអស់គ្នានឹងធ្វើខ្លួនឱ្យក្លាយជាសិស្សល្អ កូនល្អ និងមិត្តល្អ នៅក្នុងសង្គមដែលនេះគឺជាក្តីប៉ងប្រាថ្នារបស់អាណាព្យាបាលគ្រប់រូប។

នាឱកាសនោះដែរ បងស្រីតេរេសា ទួរអេឡេ នាយិកាសាលា បានឡើងមានមតិថា ដោយមើលឃើញពីការកើនឡើងនូវតម្រូវការជំនាញសម្រាប់ស្ត្រី និងការចូលរួមការពារការរីករាលដាលនៃស្ត្រីពេស្យា ក្នុងចំណោមក្មេងស្រី ដែលមិនបានចូលសាលា ដូច្នេះយើងបានសម្រេចចិត្តបង្កើតមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសាលាដុនបូស្កូទឹកថ្លា នៅឆ្នាំ១៩៩៧។ បងស្រីបន្តដោយទឹកចិត្តមោះមុតថា យើងខ្ញុំដែលជាបងស្រីសាលេស៊ានដុនបូស្កូទូទាំងពិភពលោក ជាបេសកជនដែលធ្វើការបណ្តុះបណ្តាលលើវិស័យអប់រំដើម្បីកុមារ និងយុវជនជាពិសេសយុវនារីក្រីក្រដែលជាជម្រើសមុនគេរបស់យើង។”

កំពុងអង្គុយសម្លឹងមើលក្មេងៗ និងមនុស្សម្នាដើរកាត់មុខជាច្រើន លោកតាអ៊ុក សាខុន អាយុ៧០ឆ្នាំ ជាមន្ត្រីចូលនិវត្តន៍មានចៅចំនួន ៣នាក់ កំពុងសិក្សានៅទីនោះ មានប្រសាសន៍ថា : “ខ្ញុំមានការត្រេកអរចំពោះសាលានេះ ព្រោះថាសាលាមានការអធ្យាស្រ័យច្រើនចំពោះសិស្សក្រីក្រ អ្នកដែលគ្មានលទ្ធភាព ឬមានលទ្ធភាពតិចតួច តែសាលា នៅទទួលឱ្យនៅរៀនបាន។” លោកបន្ថែមថា នៅសាលានេះ មានការរៀបចំនិងអប់រំមនុស្សបានល្អ ប្រសិនបើកូនសិស្សយកវិន័យសាលាជាគោលនោះ នៅថ្ងៃអនាគត លោកមានសង្ឃឹមថា ក្មេងៗនឹងជៀសផុតពីអំពើអបាយមុខ។ សង្គមនឹងពោរពេញដោយមនុស្សល្អ។ ប្រទេសជាតិយើងនឹងមានការរីកចម្រើន។

ជាមួយគ្នានេះដែរ អ្នកគ្រូអ៊ូម រម្សនី បានចាប់អារម្មណ៍ថា : “ខ្ញុំសប្បាយចិត្តដោយឃើញសាលានេះសម្ពោធនូវអគារថ្មី។ ខ្ញុំក៏សង្ឃឹមថា ពេលអនាគតកូនខ្មែរជាច្រើននឹងបានរៀននៅសាលានេះ។ ហើយនៅពេលដែលពួកគេធំឡើង ពួកគេនឹងមានចំណេះដឹងល្អដែលអាចជួយដល់ប្រទេសជាតិ ព្រោះពួកគេជាទំពាំងស្នងឫស្សី។” ប៉ុន្តែអ្នកគ្រូ ក៏ហាក់ដូចជាមានការព្រួយបារម្ភចំពោះអនាគតរបស់យុវជនដែរ ប្រសិនពួកគេពុំមានលទ្ធភាពរៀន និងងាកទៅធ្វើការងារផ្សេងៗ មានន័យថាពួកគេនឹងក្លាយទៅជាមនុស្សអវិជ្ជា។ ពេលនោះពួកគ្មានចំណេះវិជ្ជា និងនាំឱ្យអនាគតប្រទេសជាតិមិនបានល្អដែរ។

ចំណែកព្រះមហាក្សត្រីស៊ីសុវត្ថិពង្សនារី មុនីពង្ស មានបន្ទូលទៅកាន់ភ្ញៀវទាំងអស់ដោយព្រះភក្ត្រញញឹមថា: “ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រៀលជ្រៅសម្រាប់សាលា ដែលយកចិត្តទុកដាក់ផ្តល់នូវការអប់រំចំពោះកុមារាកុមារី យ៉ាងអស់ពីកម្លាំងកាយចិត្ត”។ បន្ទាប់ពីបានបញ្ចប់ការសំណេះសំណាលជាមួយអ្នកចូលរួមទាំងអស់ ព្រះអម្ចាស់ក្សត្រីស៊ីសុវត្ថិពង្សនារី មុនីពង្សបានយាងទតអគារ និងកាត់ខ្សែបូសម្ពោធបើកឱ្យប្រើប្រាស់ចាប់ពីពេលនោះតទៅ ជាមួយនិងស្នូរទះដៃក្នុងបរិយាកាសប្រកបដោយភាពរីករាយជាទីបំផុត។

មុំ គន្ធា

**ម្ចាស់ជំនួយ**

ដែលជួយឱ្យមានការស្ថាបនាអគារសិក្សានេះ គឺដូចជាលោក **Dong Zappelli** ព្រមទាំងក្រុមគ្រួសារមកពីប្រទេសអូស្ត្រាលី សាសនទូត និងមណ្ឌលកាតូលិកមកពីប្រទេសស្វ៊ីសគី។ **Kindermissionwerk** របស់ប្រទេសអាឡឺម៉ង់។ ក្រុមបុព្វជិតសាលេស៊ាននៃប្រទេសថៃ ក្រុមអភិបាលនៃព្រះសហគមន៍ប្រទេសអ៊ីតាលី និង **KZE Misereor** និង **Missio** របស់ប្រទេសអាឡឺម៉ង់។ អង្គការ **Room to Read** ក៏បានជួយឧបត្ថមសៀវភៅ និងសប្បុរសជនជាច្រើនទៀត ដែលចំណាយតម្លៃសរុបអស់ប្រមាណជា ៤១ ៥៥២៥ដុល្លារ។

ព្រះរាជពិធីច្រត់ព្រះនង្គ័ល បានប្រារព្ធធ្វើកាលពីថ្ងៃទី៥ ឧសភាកន្លងទៅ ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់នៃព្រះករុណា ព្រះបាទនរោត្តម សីហមុនី ជាព្រះមហាក្សត្ររបស់ព្រះរាជាណាចក្រកម្ពុជា។


Photo: L. Sovanna

ពិធីច្រត់ព្រះនង្គ័លប្រកាសអំពីរដូវធ្វើស្រែដល់កសិករ

# គោឧសភរាជឱ្យប្រផ្នូលមិនល្អ

នៅក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័លឆ្នាំ២០០៧នេះព្រះមហាក្សត្រសព្វព្រះហឫទ័យជ្រើសតាំងអ្នកអម្ចាស់នរោត្តម សិរ្វាវ័ត្ត ធ្វើជាស្ដេចនាគ និងអ្នកម្នាងជាព្រះមេហ្វូ។ ការផ្សងនៅក្នុងព្រះរាជពិធីនេះ គោឧសភរាជបរិភោគតែពោតមួយមុខប៉ុណ្ណោះក្នុងចំណោមអាហារទាំងប្រាំពីរ ដែលដាក់ផ្សង។ គោឧសភរាជបរិភោគពោតបាន ៥៥% ព្រាហ្មណ៍ព្រះរាជគ្រូព្យាករថា ទិន្នផលពោតផ្ដល់ផលនៅឆ្នាំនេះ តិចតួចណាស់។ ប៉ុន្តែនេះគ្រាន់តែជាការផ្សងនៅក្នុងព្រះរាជពិធីតាមទំនៀមទម្លាប់ពីបុរាណមកប៉ុណ្ណោះ។

លោកស្រីយ៉េត វី អាយុ៦០ឆ្នាំមកពីខេត្តព្រៃវែង ដែលមានជំនឿយ៉ាងជ្រៅលើការផ្សងនេះ បានបង្ហាញអារម្មណ៍ថា ឆ្នាំនេះយើងប្រាកដជាមានការលំបាកហើយ ពីព្រោះស្រូវវស្សាសណ្ដែក ល្ង នឹងមិនធ្វើបានផលជាទីគាប់ចិត្តឡើយ។ លោកព្រាហ្មណ៍ព្រះរាជគ្រូកង កេន បានសម្ដែងនូវការព្រួយបារម្ភថា ទោះបីជាការផ្សងតាមទំនៀមទម្លាប់ពីបុរាណក៏ពិតមែនតែកន្លងមក វាឃើញកើតមានដូចអ្វីដែលផ្សងណាស់។ ប៉ុន្តែលោកបានសម្ដែងនូវការទុកចិត្តលើយុទ្ធសាស្ត្រនយោបាយនៃរាជរដ្ឋាភិបាល ដែលយកចិត្តទុកដាក់ចំពោះប្រព័ន្ធធារាសាស្ត្រ កសាងទំនប់ ឬប្រឡាយជាច្រើនដើម្បីជាប្រយោជន៍សម្រាប់គាំពារដល់ដំណាំកសិកម្ម។

យោងតាមរបាយការណ៍បូកសរុបរបស់ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ឆ្នាំ២០០៧នេះ បង្ហាញថា នៅទូទាំងប្រទេស ការប្រមូលផលស្រូវសរុបបាន ៦២៦៤ ០៣០តោនលើសឆ្នាំកន្លងទៅ ចំនួន ២៧៧៨៥១តោន។ ក្នុងនោះ ស្រូវវស្សា ៤៩៧៣៦៩៥ តោន ហើយនិងស្រូវប្រាំងមានចំនួន ១ ២៩០ ៣៣៤តោន។ នេះគឺដោយសារប្រទេសកម្ពុជាពង្រីកផ្ទៃដីកសិកម្មបានរហូតដល់ ២៥ ៤ ១៤៣៣ហិចតា លើសឆ្នាំមុន ១០៣៣៩៦ហិចតា។ ប៉ុន្តែដោយសារតែគ្រោះរាំងស្ងួតនាំឱ្យដំណាំស្រូវវស្សាខ្លះខូចខាត ដែលការប្រមូលផលស្រូវបានលើផ្ទៃដីត្រឹមតែ ២៥ ១ ៧០៩៥ហិចតាប៉ុណ្ណោះ។

លី សុវណ្ណា

## ពិធីច្រត់ព្រះនង្គ័ល

ព្រះរាជពិធីច្រត់ព្រះនង្គ័លនេះ មានដើមកំណើតយូរយារណាស់មកហើយ ជាពិធីមួយប្រកាសថា រដូវវប្បមង្គល (មានន័យថា មង្គល សាបព្រោះ ដាំដុះ) ចូលមកហើយ ដើម្បីឱ្យប្រជាកសិករទាំងអស់ចាប់ផ្ដើមសាបព្រោះ និងធ្វើស្រែចំការ។ ខ្មែរជំនាន់ដើមតែងគោរពតាមលំអាននៃប្រពៃណីនេះណាស់។ គេស៊ូទ្រាំរង់ចាំរហូតដល់ព្រះរាជពិធីប្រារព្ធចប់សព្វគ្រប់។



# វិធីចិញ្ចឹមមាន់

នៅអ្នកនាំសារលេខមុន ប្រិយមិត្តបានដឹងខ្លះៗរួចហើយអំពីការជ្រើសរើសពូជមាន់ចិញ្ចឹម និងការរៀបចំទ្រុង។ ឥឡូវប្រិយមិត្តនឹងយល់អំពីផ្នែកផ្សេងទៀតដូចជា ការឱ្យចំណី និងការថែទាំ។


Photo: DR

កសិករព័ទ្ធជុំវិញទីធ្លាចិញ្ចឹមមាន់ដោយដាំជារបងរស់ងាយៗ

តាមប្រសាសន៍របស់លោក ប៊ុន ពេញភ័ក្ត្រ មន្ត្រីគំរោងរបស់អង្គការសេដាក បានឱ្យដឹងថា៖

### ចំណីអាហារសម្រាប់មាន់

ដើម្បីអាចលូតលាស់ និងពងបានល្អ មាន់ត្រូវការនូវចំណី ៤ ក្រុមសំខាន់ៗ គឺ ក្រុមប្រូតេអ៊ីន៖ មានជន្លេន ឬសត្វល្អិត ដូចជា កណ្ដូប កណ្ដៀរ ឬដង្កូវ។ល។ រីឯរុក្ខជាតិ មានដូចជា ពួកគ្រាប់ធញ្ញជាតិ សណ្ដែកសៀង សណ្ដែកខៀវជាដើម។ ក្រុមថាមពល៖ មានអាហារខ្លាញ់ អាហារជាតិម្សៅ និងជាតិស្ករ ដូចជា កន្ទក់ ពោត ស្រូវ និងដំឡូងឈើ។ល។ ក្រុមរ៉ែ៖ បានមកពីម្សៅសំបកខ្យងខ្ចៅ លៀស គ្រំ និងអំបិល។ល។ ក្រុមវីតាមីន៖ គឺសំបូរនៅក្នុងស្មៅស្រស់ៗ ចក កន្ធំថេត ស្លែ ស្លឹកស្ដៅ និងរុក្ខជាតិបៃតងជាច្រើនប្រភេទទៀត។

### ការដាក់ចំណីឱ្យមាន់ស៊ី

ជាទូទៅមាន់ជំទន់មួយក្បាលត្រូវការចំណីសរុបប្រហែល ១ ខាំក្នុងមួយថ្ងៃ។ នៅពេលមាន់មានអាយុពី១-១៥ ថ្ងៃដំបូង គួរតែផ្ដល់ចំណី ៤-៥ដង ក្នុងមួយថ្ងៃ លុះដល់ក្រោយមក គឺអាចបន្ថយមកនៅត្រឹម ២-៣ដង ក្នុងមួយថ្ងៃវិញ។ ចំពោះកូនមាន់ទើបនឹងញាស់ គួរតែបង្អត់អាហាររយៈពេល ១២ ម៉ោង ព្រោះថា ក្នុងខ្លួនរបស់វានៅមានសារធាតុបម្រុងជីវិតនៅឡើយ។ បើឱ្យកូនមាន់ស៊ីចំណីរហ័សពេកនោះ គឺវាអាចអួលស្លាប់។ ចំណីសម្រាប់កូនមាន់ ជាចំណីងាយរលាយ ម៉ដ្ឋ ឬមានគ្រាប់ល្អិតៗ ដូចជាកន្ទក់ ឬចុងអង្ករជាដើម។

### ការពារប្រមើលលើសំបុកមាន់ និងទម្លាក់ព្រូន

មុននឹងដាក់មេមាន់ក្រាបពង កសិករគួរដាក់ទ្រាប់បាតសំបុកដោយប្រើស្លឹកស្ដៅ ស្លឹកគ្រៃ ឬទន្រ្ទានខេត្ត។ល។ គួរទម្លាក់ព្រូនមាន់រៀងរាល់ខែ ដោយប្រើស្លឹក ឬគ្រាប់កន្ធំថេត គ្រាប់សង្កែ និងផ្លែស្លាខ្ចី-ល- លាយក្នុងចំណីឱ្យមាន់ស៊ី។

### ការធ្វើអនាម័យ និងវិធានការណ៍បង្ការជំងឺផ្សេងៗ

បរិស្ថានកន្លែងចិញ្ចឹមត្រូវស្អាត។ ពូជមាន់ថ្មីយកមកពីប្រភពផ្សេងៗ ត្រូវក្រុងដាក់ដោយឡែកយ៉ាងតិច ១៤ថ្ងៃ ដើម្បីឱ្យដឹងថាមាន់នោះពុំមានផ្ទុកជំងឺ។ បើសង្ស័យថា មាន់ណាកើតជំងឺ ត្រូវបំបែកឱ្យឆ្ងាយពីមាន់ដទៃៗ។ កសិករមិនត្រូវហូបមាន់ឈឺ ឬបោះចោលផ្ដេសផ្ដាសទេ គឺត្រូវកប់ ឬដុតចោល។

ផាត សំភី

## កន្លែងសិក្សា

ប្រសិនបើលោកអ្នកចង់សិក្សាអំពីរបៀបបច្ចេក-ទេសនៃការចិញ្ចឹមសត្វគ្រប់ប្រភេទ គឺមានបង្រៀននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) ម៉្យាងលោកអ្នកអាចអញ្ជើញបុគ្គលិកសេដាកទៅបង្រៀនដល់កន្លែងផ្ទាល់របស់លោកអ្នកដោយតម្លៃសមរម្យតាមការពិភាក្សាគ្នា។ សូមទំនាក់ទំនងទូរស័ព្ទ៖ ៎០២៣ ៨៨០ ៩១៦។



# តេតាណូស

ការមុតនឹងអ្វីផ្សេងៗតែងតែកើតឡើងដោយសារការធ្វេសប្រហែស និងភាពថែដន្យ ប៉ុន្តែបើមុតឬរងរបួសហើយ យើងមិនបានចាក់វ៉ាក់សាំងការពារ វាអាចធ្វើឱ្យកើតជំងឺតេតាណូស។

តាមប្រសាសន៍របស់លោកវេជ្ជបណ្ឌិត ឈៀ គន្ធារី នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតបានឱ្យដឹងថា ជំងឺតេតាណូសបង្កឡើងដោយពពួកមេរោគហៅថា បាក់ស៊ីលនីកូលឡាយអ៊ែរ ដែលច្រើនរស់នៅក្នុងរបស់ស្អុយ ដូចជាសំរាម ឬអាចម៍គោជាដើម។ ជំងឺនេះកើតបានដោយសារមុត ឬរងរបួស។ ទោះបីយើងមុតអ្វីក៏ដោយ កាលណារបស់ដែលមុតនោះមិនមានជាប់មេរោគ យើងមិនកើតតេតាណូសទេ។ តែបើមានមេរោគវិញ យើងអាចកើតជំងឺនេះបាន។ ជំងឺតេតាណូស បើកាលណាវាកាន់តែឆាប់សម្ដែងចេញ វាកាន់តែធ្ងន់ធ្ងរ។ បើកាលណាមុតភ្លាម ពី២ថ្ងៃ ទៅមួយអាទិត្យ បើលេចចេញជាជំងឺ គឺវាធ្ងន់ធ្ងរហើយ បើតាមធម្មតា មេរោគស្ងប់ស្ងៀមដល់ទៅ ៥០ថ្ងៃ។ រោគសញ្ញានៅពេលលេចចេញជា តេតាណូស គឺរឹងថ្គាម និយាយលែងកើត និងអ្នកជំងឺប្រកាច់ៗ។ ហើយជាពិសេស នៅពេលអ្នកជំងឺត្រូវពន្លឺថ្ងៃ ឬជួបជាមួយសម្លេងអ៊ូអរ គឺប្រកាច់ភ្លាមតែម្ដង។

កាលណាយើងមិនបានបញ្ជូនអ្នកជំងឺទៅជួបនឹងវេជ្ជបណ្ឌិតជំនាញឱ្យធ្វើការព្យាបាលទាន់ពេលវេលា អ្នកជំងឺអាចស្លាប់ដោយសារប្រកាច់ខ្លាំងពេក ដែលធ្វើឱ្យស្ទះផ្លូវដង្ហើម។ ការព្យាបាលគឺមានការលំបាក នៅពេលតេតាណូសចេញជារោគសញ្ញាហើយនោះ។ អ្នកជំងឺនឹងកន្ត្រាក់ៗ ជាញឹកញាប់ ដែលអាចធ្វើឱ្យគាត់ស្លាប់ដោយថប់ដង្ហើម។ ពេលព្យាបាលវេជ្ជ-បណ្ឌិតត្រូវដាក់អ្នកជំងឺឱ្យស្ថិតនៅក្នុងបន្ទប់មួយ ដាច់ដោយឡែក មិនឱ្យឮសូរសម្លេង ឬត្រូវពន្លឺថ្ងៃអ្វីទេ ពោលគឺត្រូវតែស្ងាត់ស្ងៀម។តាមពិតបើតេតាណូសលេចចេញធ្ងន់ធ្ងរហើយ ការព្យាបាលសង្ឃឹមជា តិចណាស់។ លោកវេជ្ជបណ្ឌិតឈៀ គន្ធារី សង្កត់ធ្ងន់ថា៖ “យកល្អ! គួរចាក់វ៉ាក់សាំងតេតាណូសឱ្យបានត្រឹមត្រូវ ដែលអាចការពារជំងឺនេះបាន ១០០%។”

ផាត សំភី


Photo: P. Samphy

វេជ្ជបណ្ឌិតឈៀ គន្ធារី នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត

## ការពារមួយជីវិត

មាតាបិតាគួរយកកូនតូចទៅចាក់វ៉ាក់សាំងការពារតេតាណូសតាមវេជ្ជបញ្ជារបស់គ្រូពេទ្យ គឺពេលគេមានអាយុ១ខែ ចាក់១ខែម្ដង រយៈពេល ៣ ខែ ១ឆ្នាំម្ដង ៥ឆ្នាំម្ដង និង១០ឆ្នាំ ម្ដងទៀត។



សូមក្រាបបង្គំទូលថ្វាយព្រះពរជ័យ

ថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម

សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងឱកាសចម្រើនព្រះជន្មគម្រប់ ៥៤ យាងចូល ៥៥ ព្រះវស្សា

**ទូលព្រះបង្គំយើងខ្ញុំ ជាអភិបាល បូជាចារ្យ បព្វជិត បព្វជិតា រួមជាមួយគ្រិស្តបរិស័ទ នៃព្រះសហគមន៍កាតូលិកនៅកម្ពុជា សូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ សូមទ្រង់ព្រះមេត្តាប្រសិទ្ធពរជ័យបវរមហាប្រសើរ ថ្វាយ ព្រះករុណាបានប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ ព្រះរាជសុខភាពបរិបូរណ៍ ព្រះកាយពលមាំមួន និង ព្រះប្រាជ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏មហាត្រជាក់ត្រជុំ ដល់ប្រជានុរាស្ត្ររបស់ព្រះអង្គជានិច្ចនិរន្តរ៍។**

## ព្រឹត្តិការណ៍សំខាន់!

- ខែឧសភា: បងស្រីសារីយ៉េ និងសុជាតិ ផ្លាស់ប្តូរទៅរស់នៅក្នុងខេត្តក្រចេះ។
- នៅព្រះសហគមន៍ស្នួងកំពុងចាប់ផ្តើមសាងសង់សាលាមត្តេយ្យសិក្សាក្នុងភូមិថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។
- ពាក់កណ្តាលខែឧសភា: ព្រះសហគមន៍សៀមរាបនឹងរៀបចំកម្មវិធីអប់រំសុជីវធម៌អនាម័យ និងការអប់រំជំនឿនៅតាមព្រះសហគមន៍នានានៅក្នុងខេត្តសៀមរាប ដែលមានរយៈពេល២-៣ថ្ងៃ។
- ព្រះសហគមន៍ចុងឃ្នាសនៅខេត្តសៀមរាបនេះដែរ កំពុងសាងសង់សាលាបឋមសិក្សានៅលើទឹកចំនួន ៣បន្ទប់ទៀត។
- ព្រះសហគមន៍ក្រុងព្រះសីហនុកំពុងរៀបចំទិញដីនៅបឹងតាព្រហ្មដើម្បីធ្វើព្រះវិហារ។
- ថ្ងៃទី២-៤ ឧសភា: ដំណើរទស្សនកិច្ចរបស់ជនជាតិអាល្លឺម៉ង់២នាក់ នៅព្រះសហគមន៍ក្តុលលើ ភូមិភាគកំពង់ចាម។
- ថ្ងៃទី០៤-០៥ ឧសភា: មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូរៀបចំបោះជំរំសម្រាប់រិះគិតអំពីជីវិតអ្នកម្តាយម៉ាសារ៉េឡូ ដែលធ្វើនៅដុនបូស្កូនារី-ទឹកថ្លា។
- ថ្ងៃទី១២ ឧសភា: ប្រជុំក្រុមសារិបតា ដែលមានគ្រួសារជាសមាជិក ៦៤គ្រួសារ នៅព្រះសហគមន៍កំពង់ចាមក្រុង។
- ថ្ងៃទី២៧ ឧសភា: ពិធីទទួលជំហានទី១ របស់បងប្អូនចំនួន ១៨នាក់ ដែលប្រារព្ធធ្វើនៅព្រះសហគមន៍កំពង់ចាមក្រុង។
- ថ្ងៃទី២០ ឧសភា: សំណាក់ធម៌អំពីប្រធានបទ និងនិទានរឿងព្រះយេស៊ូនៅក្នុងជីវិតខ្លួនម្នាក់ៗ នៅផ្សារតូច។
- ថ្ងៃទី២៧ ឧសភា: រៀបចំធ្វើអគ្គសញ្ញាលាបថ្ងាសដល់បងប្អូនជាង ២០នាក់នៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច)។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ អ៊ូមែរ ហ្សីរ៉ាល់ដូ